# ស្ទោង/ប្រាសាទបាឡាំង A1 & A3



| | | |
|---|---|---|
| **ខេត្ត** | : | កំពង់ធំ |
| **ស្រុក** | : | ស្ទោង ប្រាសាទបាឡាំង និង កំពង់ស្វាយ |
| **ផ្ទៃដី ( ហិកតា)** | : | ១០០.៦៧៥ |
| **រយៈកំពស់ ( ម៉ែត្រ)** | : | ៤ ដល់ ៧០ |
| **កូអរដោនេចំណុចកណ្តាល** | : | ១៣°០១´ជ ១០៤°៤៣´ក |

## ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះ ស្ថិតនៅភាគអគ្នេយ៍នៃតំបន់ IBA ស្ទោង / ជីក្រែង / កំពង់ស្វាយ (KH016) ហើយរួមមានតំបន់ព្រៃរបោះលាយឡំជាមួយនឹងតំបន់វាលស្មៅ បឹង និង អូរមានទឹកតាមរដូវកាល ។ តំបន IBA នេះ គឺជាតំបន់មួយក្នុងចំណោមតំបន់ពងកូនរបស់សត្វខ្សឹបដែលគេបានរកឃើញនៅពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ។ ខ្សឹបបានមករកស៊ីនៅក្នុងតំបន់នេះនៅពេលដែលតំបន់ពងកូនស្ថិតក្នុងតំបន់លិចទឹកបឹងទន្លេសាបត្រូវលិចលង់អស់ ។ លើសពីនេះទៀត ប្រភេទទីជំរកតំបន់ដីសើមក្នុងតំបន់នេះ ក៏មានសារៈសំខាន់សម្រាប់ជាតំបន់រកស៊ីរបស់ពពួកសត្វស្លាបទឹកធំៗមួយចំនួនផងដែរ ដូចជារនាលពណ៌ សត្វកសចង្កៀលខ្យង និង ត្រដក់តូច ។

## ប្រភេទសត្វស្លាបសំខាន់ៗ

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA |
|---|---|---|---|
| ខ្សឹប | Bengal Florican | *Houbaropsis bengalensis* | A1 |
| ត្រដក់តូច | Lesser Adjutant | *Leptoptilos javanicus* | A1 |
| រនាលពណ៌ | Painted Stork | *Mycteria leucocephala* | A1 |

## ប្រភេទសត្វប្រមូលផ្តុំក្នុងតំបន់មួយជាក់លាក់

មានសត្វស្លាបមួយប្រភេទរស់នៅក្នុងតំបន់ទំនាបវាលស្មៅ (សូមមើលតារាងឧបសម្ព័ន្ធ៤) ។

## ការគំរាមកំហែងលើជីវៈចំរុះ

ការគំរាមកំហែងលើជីវៈចំរុះនៅក្នុងតំបន់ IBA នេះមិនទាន់បានវាយតំលៃឱ្យបានល្អិតល្អន់នៅឡើយទេ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ការគំរាមកំហែងមួយនៃការគំរាមកំហែងចំបងៗ គឺគេគិតថា ជាការបរបាញ់សត្វស្លាបដោយអ្នកនេសាទនៅពេលដែលពួកគាត់បានជួបដោយចៃដន្យ ខណៈពេលដែលពួកគាត់កំពុងឆ្លុះត្រីក្នុងរដូវវស្សា ។ កាលពីអតីតកាល មានអ្នកប្រមាញ់មួយចំនួនមានបំណងបរបាញ់សត្វខ្សឹបនៅក្នុងតំបន់នេះ ។

## អនុសាសន៍

ការអនុវត្តន៍ច្បាប់ និង ការផ្សព្វផ្សាយចំណេះដឹងតាមមូលដ្ឋានគួរតែធ្វើឡើងដោយផ្អែកលើគំរូទទួលបានជោគជ័យនៅក្នុងតំបន់ IBA ស្ទឹងសែន / សន្ទុក / បារ៉ាយណ៍ (KH021) ។ ការងារនេះផ្តោតលើការត្រួតពិនិត្យការបរបាញ់ និង ការធ្វើពាណិជ្ជកម្ម

ប្រភេទសត្វសំខាន់ៗ ជាពិសេសខ្សឹប និង សត្វស្លាបទឹកធំៗ ព្រមទាំងផលប្រយោជន៍ដែលមានសក្តានុពលសម្រាប់សហគមន៍មូលដ្ឋាន ។

## ឯកសារយោង

Hong Chamnan (2002) *Field survey for Bengal Florican in the wet season in Kampong Thom province*. Unpublished report to the Wildlife Conservation Society Cambodia Program.